**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**OFFICE OF THE CO-INVESTIGATING JUDGES**
**BUREAU DES CO-JUGES D'INSTRUCTION**

# សហចៅក្រមស៊ើបអង្កេតអន្តរជាតិលាឈប់ពីមុខតំណែងនៅពេលបញ្ចប់សំណុំរឿង ០០៤

ចៅក្រម Michael Bohlander បានដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ការស៊ើបអង្កេតនៅសេសសល់ចុងក្រោយក្នុងសំណុំរឿង ០០៤ ត្រូវបានបញ្ចប់ត្រឹមថ្ងៃនេះ។

គាត់បានបំពេញការងារជាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៥ នៅពេលគាត់ចូលកាន់ការងារបន្តពីចៅក្រម Mark B. Harmon ក្នុងនាមជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិទី ៥ ចាប់តាំងពីការបង្កើត អ.វ.ត.ក មក។

គាត់ទទួលស្គាល់ថា នេះជាកិត្តិយស និងជាបុព្វសិទ្ធិមួយដែលបានបំពេញការងារជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបានធ្វើការរួមគ្នាជាមួយសហចៅក្រមស៊ើបអង្កេតជាតិ ឯ.ឧ យូ ប៊ុនឡេង និងក្រុមការងាររបស់គាត់។ ជាពិសេស គាត់សូមថ្លែងអំណរគុណដល់សមាជិកក្រុមការងារទាំងអស់របស់គាត់ រួមមាន បុគ្គលិក មន្ត្រីកិច្ចសន្យា និងបុគ្គលិកកម្មសិក្សា ចំពោះការងារដ៏មានតម្លៃ ការគាំទ្រ និងភាពស្មោះត្រង់របស់ពួកគេ ហួសពីភារកិច្ចដែលត្រូវបំពេញ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ទោះបីស្ថិតក្នុងស្ថានភាពលំបាកលំបិនយ៉ាងណាក្តី។

ចៅក្រម Bohlander នឹងវិលត្រឡប់ទៅប្រទេសអង់គ្លេសវិញ ដើម្បីបំពេញការងារជាប្រធានផ្នែកនីតិប្រៀបធៀប និងនីតិព្រហ្មទណ្ឌអន្តរជាតិនៅមហាវិទ្យាល័យនីតិសាស្ត្រ Durham ដែលគាត់បានសុំច្បាប់សម្រាកចាប់តាំងពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ មក។ គាត់ក៏នឹងទទួលយកការងារជាសមាជិកនៃក្រុមចៅក្រមបម្រុងនៅក្នុងអង្គជំនុំជម្រះពិសេសសម្រាប់ Kosovo នៅទីក្រុងឡាអេ ដែលគាត់បានទទួលការតែងតាំងក្នុងខែកុម្ភៈ ឆ្នាំ២០១៧។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩